ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៤៨៧ អយក.ប្រក

# ប្រកាស

ស្តីពីការពង្រីកសាលារៀនចំណេះទូទៅឯកជន " **សាលាឡូហ្គោសអន្តរជាតិ** "

ស្ថិតនៅក្នុង សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក ក្រុងភ្នំពេញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យ លេខ ១៨ អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- យោងលិខិតស្នើសុំរបស់លោកស្រី **ហង្ស ច័ន្ទថន** ចុះថ្ងៃទី ០៧ មេសា ២០០៤ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និងអភិបាលរាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សម្រេច

**ប្រការ១** : អនុញ្ញាតឱ្យពង្រីកសាលាចំណេះទូទៅឯកជន " **សាលាឡូហ្គោសអន្តរជាតិ** " ចាប់ពីកំរិតបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ស្ថិតនៅក្នុងសង្កាត់ បឹងកក់ទី២ ខណ្ឌ ទួលគោក ក្រុងភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

**ប្រការ២** : សាលារៀនឯកជន **សាលាឡូហ្គោសអន្តរជាតិ** ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សាតាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**ប្រការ៣** : លោកស្រី **ហង្ស ច័ន្ទថន** ជានាយិកាសាលាត្រូវដឹកនាំ ចាត់តាំង គ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវក្នុងការងារ :

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្រប ។
- ជ្រើសរើសសិស្សឱ្យចូលរៀន ។
- ធានាដំណើរការបង្រៀន និងរៀនឱ្យបានល្អ ។
- គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- ធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពសិក្សាជូនមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញតាមកាលកំណត់ ។

...៤ : ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលារៀននេះអនុវត្តខុសពីគោលការណ៍អប់រំរបស់រដ្ឋ ។

...៥ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងនាយិកាសាលារៀនសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ១១ ខែ ... ឆ្នាំ២០០៦

...ន ... ...

**...ន្លែងទទួល:**

- ...ីស្តីការគណៈរដ្ឋមន្ត្រី
- ...លេខាធិការដ្ឋានមុខងារសាធារណៈ
- ...ស្សួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- "ដើម្បីជ្រាបជាពត៌មាន"
- ...សាលាក្រុងភ្នំពេញ "ដើម្បីជាពត៌មាន"
- ...ចប្រការ៥
- ...លេប្បវត្តិ-ឯកសារ នា.មចទ